**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធ**
**ព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# ប្រកាសព័ត៌មាន លេខ ២៧ (ខែ មិថុនា ឆ្នាំ ២០១៦)

ក្រុមការងារគម្រោង FMIS របស់នាយកដ្ឋានព័ត៌មានវិទ្យាបានបន្តចុះពង្រឹងសមត្ថភាពលើចំណុចខ្វះខាត និងបន្តដោះស្រាយបញ្ហាប្រឈមនានាដែលទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធ FMIS ដល់មន្ត្រីដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS នៅតាមរតនាគាររាជធានី-ខេត្តចំនួន៤ ដូចជាខេត្តកំពង់ស្ពឺ កែប កំពង់ចាម និងខេត្តកណ្ដាល។ ក្រៅពីចុះពង្រឹងសមត្ថភាពដល់មន្ត្រីនៅតាមរតនាគារ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់នាយកដ្ឋានព័ត៌មានវិទ្យា បានដឹកនាំកិច្ចប្រជុំជាមួយគ្រប់ភាគីពាក់ព័ន្ធនានា ដើម្បីសម្របសម្រួលដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើងទាក់ទងនឹងដំណើរការប្រព័ន្ធ FMIS ក្នុងគោលដៅជំរុញការអនុវត្តប្រព័ន្ធដំណើរការបានកាន់តែរលូន។ ជារួម ក្រុមការងារបានដោះស្រាយបញ្ហាជាច្រើនដែលនេះបាននឹងកំពុងបញ្ជាក់ពីឆន្ទៈមោះមុត និងមានការគាំទ្រយ៉ាងសកម្មពីភាគីពាក់ព័ន្ធ ។

ជាក់ស្ដែងកាលពីពាក់កណ្ដាលខែមិថុនាកន្លងមក ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា បានដាក់ឱ្យធនាគារកាណាឌីយ៉ាប្រើប្រាស់ប្រព័ន្ធសន្ធានកម្មរបាយការណ៍ និងប្រព័ន្ធសន្ធានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធ ASYCUDA ។ ជាមួយគ្នានេះដែរ ក្រុមការងារក៏កំពុងសិក្សា និងអភិវឌ្ឍរបាយការណ៍នានា ទៅតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋាន-នាយកដ្ឋានដែលនឹងត្រូវប្រើប្រាស់ផងដែរ ។ ការដាក់ឱ្យដំណើរការប្រព័ន្ធ Electronic Fund Transfer ជាមួយប្រព័ន្ធធនាគារជាតិ កំពុងស្ថិតក្នុងដំណាក់កាលសាកល្បងប្រើប្រាស់ក្នុងប្រព័ន្ធ FMIS មុននឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលអនាគត ។ ដោយឡែក ក្រុមការងារគ្រប់គ្រងការផ្លាស់ប្ដូរនៅតែបន្តអនុវត្តការងារគ្រប់គ្រងការផ្លាស់ប្ដូរដល់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS ដោយបានផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបច្ចុប្បន្នភាពរបស់គម្រោង FMIS តាមរយៈកិច្ចប្រជុំ, គេហទំព័រ, ព្រឹត្តិការណ៍ផ្សេងៗ និងបណ្ដាញទំនាក់ទំនងសង្គមជាដើម។ ទន្ទឹមនឹងនេះ ក្រុមការងារកំពុងរៀបចំកាលវិភាគ និងឯកសារពាក់ព័ន្ធនានាសម្រាប់ចុះផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីប្រព័ន្ធ FMIS ទៅដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ដើម្បីប្រមូលធាតុចូលបន្ថែម ព្រមទាំងស្ទាបស្ទង់កម្រិតយល់ដឹងអំពីប្រព័ន្ធ FMIS ដែលព័ត៌មានទាំងនេះនឹងក្លាយជាធាតុចូលយ៉ាងសំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវអនុវត្តលើមុខងារ និងអត្ថប្រយោជន៍របស់ប្រព័ន្ធ FMIS ដល់ក្រសួង-ស្ថាប័ន នៅពេលអនុវត្តប្រព័ន្ធ FMIS ជំហានទី២ ។

ក្រុមការងារបណ្ដុះបណ្ដាលកំពុងបន្តសម្របសម្រួលដោះស្រាយរាល់បញ្ហាកើតមាន និងផ្ដល់វគ្គបណ្ដុះបណ្ដាលដើម្បីបំពេញតម្រូវការជាក់ស្ដែង និងបង្កើនចំណេះដឹងបន្ថែមដល់អ្នកប្រើប្រាស់។ ជាក់ស្ដែង កាលពីចុងខែមិថុនា ឆ្នាំ២០១៦ ក្រុមការងារបានផ្ដល់វគ្គបណ្ដុះបណ្ដាលដល់មន្ត្រីនាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គនាយកដ្ឋានថវិកា ចំនួន២៥រូប ទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធ FMIS ។ ដើម្បីឈានទៅដល់ការដាក់ឱ្យអនុវត្តគម្រោង FMIS ដំណាក់កាលទី២ ឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធិភាព ក្រុមការងារបណ្ដុះបណ្ដាលក៏កំពុងទទួលការបណ្ដុះបណ្ដាលសមត្ថភាពបន្ថែមដើម្បីពង្រឹងសមត្ថភាពកាន់តែល្អប្រសើរ។ លើសពីនេះផងដែរ ក្រុមការងារហេដ្ឋារចនា-សម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ កំពុងទទួលវគ្គបណ្ដុះបណ្ដាលបន្ថែម និងបន្តតាមដានសមត្ថភាពដំណើរការរបស់ប្រព័ន្ធ ដើម្បីធ្វើយ៉ាងណាឱ្យប្រព័ន្ធដំណើរការបានដោយរលូន និងមានសុវត្ថិភាពខ្ពស់។

***ស្ថិតក្នុងដំណាក់កាលនៃការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នេះ ក្រុមការងារសំណូមពរ និង លើកទឹកចិត្តដល់ គ្រប់អង្គភាពពាក់ព័ន្ធទាំងអស់បន្ត និង ខិតខំប្រើប្រាស់ប្រព័ន្ធ FMIS ប្រកបដោយបុរេសកម្ម និងយកចិត្តទុកដាក់ឱ្យបានខ្ជាប់ខ្ជួន ។ ក្រុមការងារនឹងបន្តផ្ដល់ការសម្រសម្រួលគ្រប់ពេលវេលា ដើម្បីដោះស្រាយរាល់បញ្ហា ក្នុងគោលបំណងអភិវឌ្ឍប្រព័ន្ធ FMIS ឱ្យកាន់តែមានភាពងាយស្រួល និង មានប្រសិទ្ធខ្ពស់ ។***